**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ: ១៦៩០..... PC.អក

# សេចក្តីជូនដំណឹង(លើកទី២)

## ស្តីពី

ការផ្គត់ផ្គង់ និងដំឡើងឧបករណ៍បច្ចេកទេសសម្រាប់ប្រព័ន្ធបញ្ជាផ្តាច់-ភ្ជាប់ ពីចំងាយ ចំនួន ០៧មុខ ជូន អគ្គិសនីខេត្តព្រះសីហនុ និងអគ្គិសនីបាត់ដំបង(ផែនការឆ្នាំ២០២៣)

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជា នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការផ្គត់ផ្គង់ និងដំឡើងឧបករណ៍បច្ចេកទេសសម្រាប់ប្រព័ន្ធបញ្ជាផ្តាច់-ភ្ជាប់ពីចំងាយ ចំនួន ០៧មុខ ជូន អគ្គិសនីខេត្តព្រះសីហនុ និងអគ្គិសនីបាត់ដំបង(ផែនការឆ្នាំ២០២៣) ។

អគ្គិសនីកម្ពុជា បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដែលមានអាសយដ្ឋាន: អាគារលេខ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០២៣ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ៖ 092 65 23 57 និង Website: www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២៣ វេលាម៉ោង ១៤:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១៥:០៥ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០២៣ ។

ក្រុមហ៊ុន/សហគ្រាសដែលចូលរួមដាក់ឯកសារដេញថ្លៃ ស្នើសុំភ្ជាប់បន្ថែមមកជាមួយនូវឯកសារដេញថ្លៃ ដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងភ្ជាប់មកជាមួយនូវ Soft Copy ដែលជាឯកសារ Scan របស់ឯកសារដេញថ្លៃនេះ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃសុក្រ ១១កើត ខែទុតិយាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២៣

**ត.ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ហាច់ ឆួច**

ចម្លងជូន ៖

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ-កាលប្បវត្តិ